multicultural health communication

NSW GOVERNMENT Health

Khmer
[DOH-7160]

# ជម្ងឺរលាកខួរក្បាលដោយមេរោគមឺរេយ៍ វ៉ាលីយ៍ (Murray Valley)

## Murray Valley Encephalitis

### តើជម្ងឺរលាកខួរក្បាលដោយមេរោគ Murray Valley ជាអ្វី ?

- ជម្ងឺរលាកខួរក្បាលដោយ Murray Valley (MVE) ជាជម្ងឺបណ្ដាលឲ្យបាត់បង់ជីវិតដោយសារសត្វមូសខាំហើយបង្កឡើងដោយវីរុសរលាកខួរក្បាលឈ្មោះ Murray Valley ។
- គេស្គាល់ជំងឺនេះផងដែរថាជា ជម្ងឺរលាកខួរក្បាលអូស្ត្រាលី ។

### តើជម្ងឺនេះកើតឡើងនៅកន្លែងណា ?

- ជាទូទៅជម្ងឺ MVE កើតឡើងនៅតំបន់ដាច់ស្រយាលនៃភាគពាយ័ព្យប្រទេសអូស្ត្រាលី ។ ជំងឺនេះកំរកើតឡើងនៅភាគខាងកើតប្រទេសអូស្ត្រាលីណាស់ ។
- រហូតមកដល់បច្ចុប្បន្ន (ខែ ឧសភា ឆ្នាំ ២០០១) គេពុំឃើញមានរបាយការណ៍ អំពីករណីនៃជំងឺនេះចំពោះមនុស្សលោកឡើយ នៅតំបន់ភាគអាគ្នេយ៍នៃប្រទេសអូស្ត្រាលី ដោយរួមទាំងរដ្ឋ NSW និងរដ្ឋវិកតូរីយ៉ាផង ចាប់តាំងពីឆ្នាំ ១៩៧៤ មក។
- ការរាវត្បាតក្នុងអតីតកាលបង្ហាញពីការឆ្លងរបស់វីរុសទៅមនុស្សដែលរស់នៅភាគខាងលិចនៃរដ្ឋNSW ។

### តើជម្ងឺនេះរាលដាលយ៉ាងដូចម្ដេច ?

- វីរុស MVE ឆ្លងតាមរយៈមូសខាំដែលមានផ្ទុកវីរុសនេះ
- មិនមែនគ្រប់មូសទាំងអស់សុទ្ធតែផ្ទុកវីរុសនេះទេ
- ពពួកមូសដែលច្រើនផ្ទុកវីរុសជាងគេបំផុតគឺប្រភេទមូស Culex annulirostris ។ មានមនុស្សតែម្នាក់គត់ក្នុងចំណោមមនុស្សប្រហែលជា ១០០០ នាក់ ដែលនឹងកើតជម្ងឺនេះ ក្រោយពីបានឆ្លងរោគនេះតាមរយៈមូសខាំ។
- វីរុសនេះមាននៅក្នុងខ្លួនបក្សីទឹក ។ មូសឆ្លងមេរោគនេះដោយសារវាខាំបក្សី ឬ សត្វពាហនៈផ្សេងទៀតដែលមានផ្ទុកវីរុសនោះដែរ ។ ការឆ្លងរាលដាលចូលទៅផ្នែកអាគ្នេយ៍នៃប្រទេសអូស្ត្រាលី ត្រូវបានគេគិតថាកើតឡើងដោយសារបំលាស់ទីតាំងរបស់បក្សីទឹក ដែលជាទូទៅកើតមានឡើងតាមស្ថានភាពសំណើមនៅក្នុងតំបន់ដីគោកនៅប្រទេសអូស្ត្រាលី ។

### តើនរណាប្រឈមគ្រោះថ្នាក់ខ្លាំងជាងគេ?

ជម្ងឺនេះបង្កគ្រោះថ្នាក់ដល់ជីវិតប្រហែល ២០% នៃអ្នកដែលបានឈឺ ហើយច្រើនជាង ២៥% ទៀតអាចវិវឌ្ឍទៅរកផលវិបាកស្ទុះស្នាញផ្នែកសតិបញ្ញា និង/ឬ ផលវិបាកស្ទុះស្នាញនៃសរសៃប្រសាទ។ ប្រហែល ៥០% នៃករណីទាំងនោះ នឹងជាសះស្បើយទាំងស្រុង ។

**តើរោគសញ្ញាមានអ្វីខ្លះ ?**

- ជម្ងឺនេះនឹងស្តែងឡើងក្នុងរវាង ៥-១៥ ថ្ងៃបន្ទាប់ពីមូសដែលមានផ្ទុកមេរោគខាំ ។
- ភាគច្រើនបំផុតនៃមនុស្សដែលបានឆ្លង MVE នឹងគ្មានរោគសញ្ញាអ្វីទាំងអស់

ក្នុងចំណោមអ្នកដែលមានរោគសញ្ញាអាចមានរោគសញ្ញា ៖

- ឈឺក្បាលខ្លាំង
- រឹងកញ្ចឹងក
- ក្តៅខ្លួន
- ញ័រដៃជើង
- ប្រកាច់ (ជាពិសេសចំពោះក្មេងតូចៗ)
- វង្វេងវង្វាន់
- ក្អួត
- ចង្អោរ
- រាក
- វិលមុខធីងធោង
- អស់កម្លាំងខ្សោះខ្សែះ, មួម៉ៅ, ងងុយដេក
- សន្លប់ (ក្នុងករណីធ្ងន់ធ្ងរ)
- មនុស្សដែលធ្លាប់មានរោគសញ្ញាទាំងនេះគួរស្វែងរកការព្យាបាល។

**ការបង្ការ**

គ្មានការព្យាបាល ឬវ៉ាក់សាំងជាក់លាក់ សំរាប់ MVE ទេ។ ការការពារតែមួយគត់ដើម្បីជៀសវាងជម្ងឺនេះគឺកុំឲ្យមូសខាំ ។ ការការពារនេះមានសារសំខាន់ជាពិសេស ចំពោះអ្នកដំណើរនិងអ្នកទេសចរទៅកាន់តំបន់ដែលអាចមាន MVE ។

**ការពារខ្លួនអ្នកផ្ទាល់កុំឲ្យមូសខាំ :**

ការការពារមូសក្នុងរដូវកាលនៃការឃាឃីរបស់ MVE មានសារសំខាន់ណាស់ ៖

- ជៀសវាងចេញទៅក្រៅនៅពេលដែលមូសមានសកម្មភាពខ្លាំង ជាពិសេសនៅពេលព្រឹកព្រលឹមនិងចន្លោះពេលមុនថ្ងៃលិចទៅពាក់កណ្តាលល្ងាច ។
- ប្រើសំលៀកបំពាក់រលុងហើយមានពណ៌ស្រាលព្រឿងៗ ព្រមទាំងមានដៃវែងជើងវែងនិងស្រោមជើង។ មូសអាចខាំតាមរយៈការស្លៀកពាក់រឹបតឹង។
- ប្រើថ្នាំលាបបណ្តេញសត្វល្អិតនៅពេលទៅក្រៅផ្ទះនិងប្រើប្រាស់ថ្នាំលាបនោះឡើងវិញនៅពេលសមស្រប។ ថ្នាំទឹកនិងថ្នាំលាបមានប្រសិទ្ធភាពជាង ហើយស្ថិតនៅបានយូរជាងថ្នាំបាញ់។
- ត្រូវធ្វើឲ្យប្រាកដថាសំណាញ់ការពារមូសត្រូវមានដាក់គ្រប់ទ្វារទាំងអស់និងមានសភាពល្អ ។ ប្រសិនបើមានការ បោះជំរំនៅខាងក្រៅត្រូវដេកក្នុងមុង ឬ ក្នុងតង់ដែលមូសមិនអាចចូលបាន។
- មុនពេលចូលដេកត្រូវបាញ់ថ្នាំមូស ់កំចាត់មូស់ ដើម្បីសំលាប់មូសដែលមាននៅក្នុងបន្ទប់។

## ព័ត៌មានបន្ថែម - ផ្នែកសុខភាពសាធារណៈ (Public Health) នៅក្នុងរដ្ឋ NSW



**1300 066 055** www.health.nsw.gov.au